ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# នីតិវិធីប្រតិបត្តិស្តង់ដារ
# សម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាល
# អ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

ថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២១

Version 1.0

# អារម្ភកថា

នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ បានរៀបចំឡើងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

នីតិវិធីប្រតិបត្តិស្តង់ដារនេះ បានផ្តោតជាសំខាន់ទៅលើ ការកំណត់លក្ខខណ្ឌក្នុងការបិទទីតាំង និងតំបន់ក្នុងការអនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ ការកំណត់យន្តការ គោលការណ៍អនុវត្តសម្រាប់អ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ការបង្ការនិងការត្រួតពិនិត្យការចម្លងរោគសម្រាប់អ្នកថែទាំ ការគ្រប់គ្រង សន្តិសុខសណ្តាប់ធ្នាប់នៅតាមគោលដៅ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការគ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ក្នុងគំនិតផ្តួចផ្តើមរួមមួយ ដ៏សំខាន់សម្រាប់ការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩។ ការរៀបចំបង្កើតនីតិវិធីស្តង់ដារនេះ ត្រូវបានចំណាយពេលវេលាខ្លី ប៉ុន្តែបានប្រមូលគំនិត មតិយោបល់ ពីអ្នកជំនាញបច្ចេកទេសដ៏ច្រើន និងផ្អែកទៅលើបទពិសោធន៍ជាក់ស្តែងនៃការគ្រប់គ្រងអ្នកជំងឺកូវីដ-១៩ នៅកម្ពុជា និងបទពិសោធន៍នៃបណ្តាប្រទេសជាច្រើនដែលបានជ្រើសរើសយកការព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះ។

ក្នុងនាមក្រសួងសុខាភិបាល និងគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ខ្ញុំសូមថ្លែងអំណរគុណក្រុមការងារផ្នែកវេជ្ជសាស្រ្ត ដែលមានសមាសភាពមកពី ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ ដែលបានចូលរួមរៀបចំជានីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ដ៏មានសារៈសំខាន់នេះឡើង។ ក្រសួងសុខាភិបាលសង្ឃឹមយ៉ាងមុតមាំចំពោះកិច្ចសហការដ៏ល្អ ក្នុងការអនុវត្ត និតិវិធីស្តង់សម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះនៅគ្រប់មូលដ្ឋានសុខាភិបាល។ ក្រសួងនឹងធ្វើការបណ្តុះបណ្តាលក្រុមគ្រូពេទ្យ និងក្រុមការងារពាក់ព័ន្ធទាំងអស់ ដោយអនុវត្តតាមនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) សម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះចាប់ពីពេលនេះតទៅ។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការ**
**អន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម_ប៊ុនហេង**

# សេចក្តីថ្លែងអំណរគុណ

| | |
|---|---|
| ១. ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ<br>និងជាមេបញ្ជាការកងទ័ពជើងគោក |
| ២. លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** | អនុប្រធានក្រុមប្រឹក្សាភិបាល សមាគមគ្រូពេទ្យស្ម័គ្រចិត្ត<br>យុវជនសម្តេចតេជោ |
| ៣. ឯកឧត្តមសាស្ត្រាចារ្យ **ហ៊ុន ចំរើន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៤. ឯកឧត្តមវេជ្ជបណ្ឌិត **ថ៉ូវ ភាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៥. ឯកឧត្តម **ចាន់ សុធី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦. ឯកឧត្តមវេជ្ជបណ្ឌិត **ហុក គឹមចេង** | អគ្គនាយកបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល |
| ៧. ឯកឧត្តមសាស្ត្រាចារ្យ **សាផុន វឌ្ឍនៈ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៨. ឯកឧត្តមសាស្ត្រាចារ្យ **ងី ម៉េង** | ទីប្រឹក្សាក្រសួងសុខាភិបាល<br>និងជានាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត |
| ៩. ឯកឧត្តមវេជ្ជបណ្ឌិត **ស៊ឹម ស៊ូយ៉េង** | ទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| ១០. ឧត្តមសេនីយ៍ត្រី **ម៉ុក ច័ន្ទសុធា** | នាយរងការិយាល័យទី២ កជគ |
| ១១. វរសេនីយ៍ឯក **មៃ ស៊ីថន** | ជំនួយការមេបញ្ជាការកងទ័ពជើងគោក |
| ១២. លោកសាស្ត្រាចារ្យ **ចាប សៀកឆាយ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល |
| ១៣. លោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ១៤. លោកបណ្ឌិត **ភុយ វីរីយ៉ា** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ១៥. លោកស្រីឱសថការី **វ៉ា ពុធនាថ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១៦. លោកវេជ្ជបណ្ឌិត **ភប វណ្ណដា** | មន្ត្រីបច្ចេកទេសរបស់អង្គការសុខភាពពិភពលោក |

# បញ្ជីមាតិកា


១. សេចក្តីផ្តើម ..... 4

២. គោលបំណង និងវិសាលភាព ..... 4

៣. ការកំណត់លក្ខខណ្ឌសម្រាប់អនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ ..... 5

៤. ការកំណត់លក្ខខណ្ឌក្នុងការបិទទីតាំង និងតំបន់ក្នុងការអនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ ..... 6

៥. ការកំណត់យន្តការ ..... 7

៦. ការសម្រេចចិត្តថែទាំព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ..... 8

៧. គោលការណ៍អនុវត្តសម្រាប់អ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ..... 10

៨. គោលការណ៍សម្រាប់គ្រូពេទ្យព្យាបាលដែលផ្តល់ការថែទាំព្យាបាលនៅតាមផ្ទះ ..... 11

៩. គោលការណ៍ស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគសម្រាប់អ្នកថែទាំដែលផ្តល់ការថែទាំព្យាបាលនៅតាមផ្ទះ ..... 13

១០. គោលការណ៍ និងបទដ្ឋានប្រតិបត្តិសម្រាប់កម្លាំងគាំទ្រ ដូចជាអាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ ..... 15

## ១. សេចក្តីផ្តើម

ជំងឺកូវីដ-១៩ គឺជាជំងឺឆ្លងរាលដាលថ្មី ដែលបណ្តាលឲ្យមានបណ្តុំរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARS-CoV-2)។ ចាប់តាំងពីការលេចចេញនូវជំងឺនេះនៅចុងឆ្នាំ២០១៩ វីរុសនេះបានរីករាលដាលយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោក ដែលបណ្តាលឱ្យមានអត្រាមរណភាព និងអត្រាជំងឺកើនឡើងយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់ ហើយបណ្តាលឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ច និងសង្គមយ៉ាងធ្ងន់ធ្ងរ ប៉ុន្តែការប៉ាន់ប្រមាណនាពេលបច្ចុប្បន្ន ករណីស្លាប់ដោយជំងឺកូវីដ-១៩ ស្ថិតនៅចន្លោះ ០,៦% - ៣,៤% ។ ការប៉ាន់ប្រមាណទាំងនេះ នឹងផ្លាស់ប្តូរនៅពេលទិន្នន័យទាំងនោះរាប់បញ្ចូលអ្នកជំងឺស្រាល និងអ្នកគ្មានរោគសញ្ញាទាំងអស់។ បទពិសោធន៍នៃបណ្តាប្រទេសជាច្រើនបានជ្រើសរើសយកការព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះ ហើយអង្គការសុខភាពពិភពលោក (WHO) ក៏បានណែនាំសម្រាប់ថែទាំអ្នកជំងឺកូវីដ-១៩ ក្នុងកម្រិតស្រាល ដែលអាចដាក់ឱ្យនៅដាច់ដោយឡែកព្យាបាលនៅតាមផ្ទះ ដើម្បីកាត់បន្ថយបន្ទុករបស់ប្រព័ន្ធសុខាភិបាល។

តាមការប៉ាន់ស្មាននៅក្នុងប្រទេសកម្ពុជា បញ្ជាក់ថាមានអ្នកជំងឺកូវីដ-១៩ ចំនួន ៨០% ស្ថិតក្នុងកម្រិតគ្មានរោគសញ្ញា និងកម្រិតស្រាល ដូច្នេះ អ្នកជំងឺកូវីដ-១៩ កម្រិតស្រាល ដែលគ្មានកត្តាប្រឈមអាចទទួលការព្យាបាលនៅតាមផ្ទះ ក្រោមការគ្រប់គ្រង ថែទាំ និងព្យាបាលជាប់ជាប្រចាំដោយមន្ត្រី-បុគ្គលិកសុខាភិបាល និងអ្នកស្ម័គ្រចិត្ត ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវដើម្បីអនុវត្តនៅតាមមូលដ្ឋាន និងតាមការវាយតម្លៃផ្ទះរបស់អ្នកជំងឺឲ្យបានហ្មត់ចត់ជាមុនពីមន្ត្រី-បុគ្គលិកពាក់ព័ន្ធ។ ជាមួយគ្នានេះ ដើម្បីកាត់បន្ថយការចម្លងជំងឺកូវីដ-១៩ ទៅសមាជិកគ្រួសារ ឬសហគមន៍ អ្នកជំងឺកូវីដ-១៩ សមាជិកគ្រួសារ មន្ត្រីសុខាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តគោលការណ៍ការបង្ការនិងត្រួតពិនិត្យការចម្លងរោគឱ្យបានខ្ជាប់ខ្ជួន។

នីតិវិធីប្រតិបត្តិស្តង់ដារនេះជាការណែនាំគ្រឹះសម្រាប់ការគ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

## ២. គោលបំណង និងវិសាលភាព

គោលបំណងនៃនីតិវិធីប្រតិបត្តិស្តង់ដារនេះគឺដើម្បីកំណត់ពីវិធាន និងនីតិវិធីសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតគ្មានរោគសញ្ញា និងកម្រិតស្រាល។

នីតិវិធីប្រតិបត្តិស្តង់ដារមានវិសាលភាពអនុវត្តចំពោះមន្ត្រីសុខាភិបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងអ្នកជំងឺកូវីដ-១៩ ក្រុមគ្រួសារ និងសហគមន៍។

### និយមន័យ

**ករណីគ្មានរោគសញ្ញា**

- គ្មានរោគសញ្ញា ឬគ្មានសញ្ញានៃការបង្ករោគ

**ករណីស្រាល**

- មានផ្ដាសាយ ហៀរសំបោរ ឈឺបំពង់ក ឈឺសាច់ដុំ និងសន្លាក់ កំដៅតិចជាង ៣៨អង្សាសេ និង
- កំហាប់អុកស៊ីសែន ($SpO_2$) ចាប់ពី ៩៥% ឡើង និង
- ចង្វាក់ដង្ហើមធម្មតា (១៨ - ២០ដង/នាទី សម្រាប់មនុស្សពេញវ័យ)
- មិនមែនជាជនងាយប្រឈម (ស្ត្រីមានផ្ទៃពោះ កុមារ និងចាស់ជរា)

## ៣. ការកំណត់លក្ខខណ្ឌសម្រាប់អនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ

ការដាក់អ្នកជំងឺកូវីដ-១៩ ឱ្យនៅដាច់ដោយឡែកព្យាបាលនៅតាមផ្ទះ មានសារៈសំខាន់ជួយកាត់បន្ថយបន្ទុកប្រព័ន្ធសុខាភិបាល ដោយផ្តល់ឱ្យមូលដ្ឋានថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នូវលទ្ធភាពបន្ថែមទៀតក្នុងការគ្រប់គ្រងករណីជំងឺកូវីដ-១៩ ធ្ងន់ធ្ងរ និងសង្គ្រោះបន្ទាន់កម្រិតធ្ងន់។

ដើម្បីកំណត់ការអនុវត្តន៍ការព្យាបាលនៅតាមផ្ទះ ត្រូវពិចារណាលើសមត្ថភាពដាក់ឱ្យសម្រាកពេទ្យនៃមូលដ្ឋានថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមបណ្តារាជធានី-ខេត្ត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយផ្អែកលើចំនួនគ្រែ (មានគ្រូពេទ្យព្យាបាល គិលានុបដ្ឋាកថែទាំ និងបំពាក់សម្ភារៈបរិក្ខារពេទ្យគ្រប់គ្រាន់) ចំនួននិងរបាយករណីជំងឺកូវីដ-១៩ ថ្មីប្រចាំថ្ងៃ និងស្ថានភាពសុខភាពនៃអ្នកជំងឺកូវីដ-១៩។ ផ្អែកលើបទពិសោធន៍ជាក់ស្តែងនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត៖

- ៥% នៃអ្នកជំងឺកូវីដ-១៩ ត្រូវការសង្គ្រោះបន្ទាន់កម្រិតធ្ងន់ (ICU)
- ១៥% នៃអ្នកជំងឺកូវីដ-១៩ ត្រូវការសង្គ្រោះបន្ទាន់ (Emergency)
- ៨០% នៃអ្នកជំងឺកូវីដ-១៩ ត្រូវការការតាមដាន និងត្រួតពិនិត្យសុខភាព

ខណៈ ៦០% នៃចំនួនគ្រែសម្រាកពេទ្យសម្រាប់ជំងឺកូវីដ-១៩ ត្រូវបានប្រើប្រាស់ នោះជាសញ្ញាអាសន្នលើកទី១ ដែលគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ត្រូវត្រៀមដាក់ឱ្យដំណើរការ៖

- ក្រុមគ្រូពេទ្យថែទាំ និងព្យាបាលនៅតាមផ្ទះសម្រាប់អ្នកជំងឺកូវីដ-១៩ ដើម្បីតាមដាន និងត្រួតពិនិត្យសុខភាព វិធានការអនាម័យ ក្នុងការដាក់ឱ្យនៅដោយឡែកអ្នកជំងឺកូវីដ-១៩ និងការអនុវត្តវិធានចត្តាឡីស័កសមាជិកគ្រួសារផ្សេងទៀត
- ក្រុមអាជ្ញាធរពាក់ព័ន្ធ ដើម្បីគ្រប់គ្រងឱ្យបានត្រឹមត្រូវ ការដាក់ឱ្យនៅដោយឡែកអ្នកជំងឺកូវីដ-១៩ អ្នកត្រូវអនុវត្តវិធានចត្តាឡីស័ក និងទីតាំង ព្រមទាំងបរិវេណជុំវិញ
- ផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ដើម្បីយល់ដឹង និងត្រៀមលក្ខណៈជាមុន អនុវត្តន៍ការដាក់ឱ្យនៅដោយឡែក ក្នុងករណីសមាជិកគ្រួសារមានការឆ្លងជំងឺកូវីដ-១៩ ដាយថាហេតុ។

ក្នុងករណី ៧០-៨០% នៃចំនួនគ្រែសម្រាកពេទ្យត្រូវបានប្រើប្រាស់ គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ត្រូវចាប់ផ្តើមអនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ ដោយរក្សាទុក ២០%-៣០% នៃចំនួនគ្រែសម្រាកពេទ្យសម្រាប់អ្នកជំងឺកូវីដ-១៩ សម្រាប់អ្នកជំងឺដែលមិនអាចអនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ មានលក្ខខណ្ឌអាយុ បញ្ហាសុខភាព និងជំងឺរួមផ្សំ សេចក្តីត្រូវការសង្គ្រោះបន្ទាន់ (Emergency) និងសង្គ្រោះបន្ទាន់កម្រិតធ្ងន់ (ICU)។

ការអនុវត្តការព្យាបាលនៅតាមផ្ទះ អាចចាប់ផ្តើមនៅរាជធានី-ខេត្តណាមួយ អាស្រ័យទៅតាមស្ថានភាពផ្ទុះជំងឺកូវីដ-១៩ ថ្មីកើនឡើងច្រើនគួរឱ្យកត់សំគាល់ ដោយមិនចាំបាច់ចាប់ផ្តើមនៅទូទាំងប្រទេសឡើយ។

## ៤. ការកំណត់លក្ខខណ្ឌក្នុងការបិទទីតាំង និងតំបន់ក្នុងការអនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ

ក្នុងការអនុវត្តន៍គោលការណ៍ព្យាបាលនៅតាមផ្ទះ ដើម្បីកាត់ផ្តាច់ខ្សែសង្វាក់ចម្លងវីរុសកូវីដ-១៩ តាមរយៈការដាក់អ្នកជំងឺកូវីដ-១៩ ឱ្យនៅដាច់ដោយឡែកនៅក្នុងផ្ទះ និងអនុវត្តវិធានចត្តាឡីស័កចំពោះអ្នកប៉ះពាល់ ព្រមទាំងពិចារណាគម្រោងការបើកឡើងវិញឱ្យបានទាន់ពេលវេលា និងសមស្រប បន្ទាប់ពីលែងមានបញ្ហាប្រឈមនឹងករណីឆ្លងកូវីដ-១៩ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់ទៅលើសេដ្ឋកិច្ច និងសង្គម។

គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ជាអ្នកអនុវត្តវិធានការណ៍រឹតត្បិតមុនឈានទៅ បិទទីតាំង តំបន់ឬផ្នែកខ្លះនៃតំបន់ដែលមានករណីឆ្លងជំងឺកូវីដ-១៩។ ដើម្បីអនុវត្តគោលការណ៍ព្យាបាលនៅតាមផ្ទះ និងអនុវត្តវិធានចត្តាឡីស័កចំពោះអ្នកប៉ះពាល់ ដោយផ្អែកលើលទ្ធផលវាយតម្លៃបច្ចេកទេស ដូចខាងក្រោម៖

1. ដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ ដោយឃ្លុំផ្ទះ ប្រសិនបើផ្ទះនៅដាច់ដោយឡែកពីផ្ទះផ្សេងទៀត
2. ដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ ដោយឃ្លុំប្លុកផ្ទះ ប្រសិនយ៉ាងហោច ផ្ទះពីរ-បីនៅជិតៗគ្នា មានដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ។ ការឃ្លុំប្លុកផ្ទះត្រូវធ្វើការពិចារណាឱ្យបានម៉ត់ចត់ ក្នុងករណីដែលផ្ទះជាប់គ្នា គ្មានករណីឆ្លងកូវីដ-១៩ ឬប៉ះពាល់ជាមួយអ្នកជំងឺ។
3. ដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ ដោយឃ្លុំភូមិ ចាប់ពី ៥% នៃចំនួនផ្ទះសរុបនៅក្នុងភូមិ មានដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ ឬប្លុកផ្ទះពីរ-បី នៅជាប់ពីគ្នា មានដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ
4. ដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ ដោយឃ្លុំឃុំ ចាប់ពី ៣០% នៃចំនួនភូមិនៅក្នុងឃុំ ដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ
5. ដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ ដោយឃ្លុំស្រុក ចាប់ពី ៣០% នៃចំនួនឃុំនៅក្នុងស្រុក មានដាក់អ្នកជំងឺកូវីដ-១៩ ព្យាបាលនៅតាមផ្ទះ។

## ៥. ការកំណត់យន្តការ

**ការទទួលខុសត្រូវរបស់អ្នកជំងឺ**

- ព្រមធ្វើកិច្ចសន្យាយល់ព្រមព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះ (ឧបសម្ព័ន្ធ ១)
- តាមដានកំដៅ ២ដងក្នុងមួយថ្ងៃ និងសុខភាពទូទៅ
- នៅដាច់ពីសមាជិកក្រុមគ្រួសារ
- ធ្វើអនាម័យផ្លូវដង្ហើម ពេលក្អក ឬកណ្តាស់។ បើប្រើក្រដាស ត្រូវដាក់ក្នុងធុងសម្រាមរួចដុតចោល
- ពាក់ម៉ាសជាប់ជានិច្ច (លើកលែងនៅម្នាក់ឯង)
- ធ្វើអនាម័យដៃជាមួយអាល់កុល ឬជាមួយទឹក និងសាប៊ូជាញឹកញាប់
- សំរាម ត្រូវដាក់ក្នុងថង់ប្លាស្ទិក និងយកទៅដុតកំទេចចោល
- បោកគក់សម្លៀកបំពាក់ កម្រាលពូក កន្សែង/ក្រម៉ា មុង ភួយជាមួយទឹក រួចបោកជាមួយសាប៊ូ និងហាលឱ្យបានស្ងួតល្អ។

**ការទទួលខុសត្រូវរបស់អ្នកថែទាំ និងអ្នកស្នាក់នៅរួមជាមួយអ្នកជំងឺ**

- តាមដានសុខភាពរបស់អ្នកជំងឺកូវីដ-១៩ ដោយប្រើទូរសព្ទ ឬសាកសួរពីចម្ងាយ
- មិនត្រូវប្រើរបស់របរ សម្ភារៈ ឬបន្ទប់ទឹករួមគ្នាជាមួយអ្នកជំងឺកូវីដ-១៩
- ពាក់ម៉ាសជាប់ជានិច្ច
- ធ្វើអនាម័យដៃជាមួយអាល់កុល ឬជាមួយទឹក និងសាប៊ូជាញឹកញាប់
- តាមដានសុខភាពផ្ទាល់ដូចជា ក្តៅខ្លួន អស់កម្លាំង (fatigue) ក្អក (មាន ឬមិនមានស្លេស្ម) ឈឺសាច់ដុំ ឈឺក ហត់បន្តិចបន្តួច តឹងច្រមុះ និង ឈឺក្បាល។
- ជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន ឬក្រុមគ្រូពេទ្យក្នុងករណីស្ថានភាពសុខភាពមានការប្រែប្រួល។

**ការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន**

- ទំនាក់ទំនងជាមួយអ្នកជំងឺកូវីដ-១៩ និងក្រុមគ្រួសារអ្នកជំងឺដោយរក្សាគម្លាតសុវត្ថិភាព
- ទំនាក់ទំនងជាមួយក្រុមគ្រូពេទ្យព្យាបាល
- រក្សាសន្តិសុខ និងសុវត្ថិភាពនៅទីកន្លែងព្យាបាលអ្នកជំងឺកូវីដ-១៩ ស្នាក់នៅ។

**ការទទួលខុសត្រូវរបស់ក្រុមគ្រូពេទ្យព្យាបាល**

- តាមដានសុខភាពអ្នកជំងឺកូវីដ-១៩ ២ដងក្នុង១ថ្ងៃតាមរយៈទូរសព្ទ Hotline
- ចុះទៅពិនិត្យសុខភាពផ្ទាល់ក្នុងករណីអ្នកជំងឺកូវីដ-១៩មានសុខភាពប្រែប្រួលដោយប្រើឧបករណ៍ការពារខ្លួន (PPE) ឱ្យបានសមស្រប
- ផ្តល់ការថែទាំ និងព្យាបាលតាមរោគសញ្ញា: ថ្នាំបញ្ចុះកំដៅ ដំបូន្មាន និងការណែនាំលើចំណីអាហារ ការបង្គ្រប់ជាតិទឹក និងជីវជាតិផ្សេងៗ។
- កំណត់សញ្ញាគ្រោះថ្នាក់លើអ្នកជំងឺ និងទំនាក់ទំនងពិគ្រោះជាបន្ទាន់ ដើម្បីធ្វើការបញ្ជូនទៅកាន់មូលដ្ឋានសុខាភិបាលដែលបានកំណត់ (សូមមើលតារាង ក្នុងចំណុចលេខ ៦.២)។
- តាមដានសុខភាពខ្លួនឯងឱ្យបានទៀតទាត់

## ៦. ការសម្រេចចិត្តថែទាំព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

បន្ទាប់ពីទទួលបានលទ្ធផលតេស្តវិជ្ជមានពីមន្ទីរពិសោធន៍ មន្ទីរសុខាភិបាលរាជធានី-ខេត្តត្រូវផ្តល់ព័ត៌មានអំពីលទ្ធផលវិជ្ជមាននេះដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដើម្បី៖

- ចាត់តាំងក្រុមមន្ត្រីសុខាភិបាលដែលទទួលបន្ទុកនៅភូមិសាស្ត្រដែលមានអ្នកជំងឺកូវីដ-១៩ កំពុងរស់នៅឱ្យវាយតម្លៃពីលទ្ធភាពក្នុងការធ្វើការថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ។
- សុំការសហការជាមួយក្រុមអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំ និងគ្រប់គ្រងទីតាំងដែលត្រូវដាក់ឱ្យព្យាបាលនៅតាមផ្ទះ។

### ៦.១. របៀបនៃការកំណត់លទ្ធភាពថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

ក្រុមមន្ត្រីសុខាភិបាលទទួលបន្ទុក និងក្រុមអាជ្ញាធរមូលដ្ឋានសហការគ្នាទៅត្រួតពិនិត្យ និងវាយតម្លៃពីលទ្ធភាពក្នុងការធ្វើការថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ដោយផ្អែកលើកត្តាចំនួន៣សំខាន់ៗ៖

- ការវាយតម្លៃគ្លីនិក និងស្ថានភាពអ្នកជំងឺកូវីដ-១៩
- ការវាយតម្លៃស្ថានភាពផ្ទះរបស់អ្នកជំងឺកូវីដ-១៩
- លទ្ធភាពក្នុងការតាមដានការវិវត្តស្ថានភាពអ្នកជំងឺកូវីដ-១៩ នៅផ្ទះ

#### ក. ការវាយតម្លៃគ្លីនិក និងស្ថានភាពអ្នកជំងឺកូវីដ-១៩

អ្នកជំងឺកូវីដ-១៩ ដែលអាចទទួលការថែទាំ និងព្យាបាល នៅតាមផ្ទះ ត្រូវតែ៖

- ពុំមានរោគសញ្ញា ឬមានរោគសញ្ញាកម្រិតស្រាល (ដូចជា៖ ក្តៅខ្លួន អស់កម្លាំង (fatigue) ក្អក (មានឬមិនមានស្លេស្ម) ឈឺសាច់ដុំ ឈឺក តឹងច្រមុះ និង ឈឺក្បាល)
- កម្រិត $SpO_2 \geq 95\%$
- គ្មានកត្តាប្រឈម ឬហានិភ័យ (ឧ. អាយុច្រើន >៦០ឆ្នាំ ជក់បារី ធាត់ មានជំងឺប្រចាំកាយ ដូចជា ជំងឺសរសៃឈាមឬបេះដូង ទឹកនោមផ្អែម ជំងឺសួតរ៉ាំរ៉ៃ ជំងឺតម្រងនោមរ៉ាំរ៉ៃ មានប្រព័ន្ធរាងកាយខ្សោយ ឬជំងឺមហារីក ។ល។)

ក្នុងករណីអ្នកជំងឺត្រូវបញ្ជូន សូមពិនិត្យតារាង ក្នុងចំណុចលេខ ៦.២ ខាងក្រោម។

#### ខ. ការវាយតម្លៃស្ថានភាពផ្ទះរបស់អ្នកជំងឺកូវីដ-១៩

ផ្ទះដែលអាចសមស្របសម្រាប់ដាក់អ្នកជំងឺកូវីដ-១៩ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- បន្ទប់រស់នៅ និងបន្ទប់ទឹក ដាច់ដោយឡែកពីសមាជិកគ្រួសារដទៃទៀត
- អាចកំណត់ចលនាអ្នកជំងឺពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងផ្ទះបាន
- សមាជិករស់នៅក្នុងផ្ទះជាមួយអ្នកជំងឺមិនមែនជាក្រុមប្រឈមមុខខ្ពស់នឹងជំងឺកូវីដ-១៩។

#### គ. លទ្ធភាពក្នុងការតាមដានការវិវត្តស្ថានភាពអ្នកជំងឺកូវីដ-១៩ នៅផ្ទះ

ពិនិត្យមើលសមាជិកនៅក្នុងគ្រួសារជាមួយអ្នកជំងឺកូវីដ-១៩ ដែលមានលទ្ធភាពតាមដានការវិវត្តរបស់អ្នកជំងឺកូវីដ-១៩ សម្របសម្រួលជាមួយក្រុមគ្រូពេទ្យព្យាបាល និងអាជ្ញាធរមូលដ្ឋាន។




## ៦.២. លក្ខខណ្ឌត្រូវបញ្ជូនអ្នកជំងឺកូវីដ-១៩ ដែលកំពុងថែទាំព្យាបាលនៅផ្ទះឱ្យទៅព្យាបាលនៅមូលដ្ឋានសុខាភិបាល

សម្រាប់អ្នកជំងឺកូវីដ-១៩ ដែលមានលក្ខខណ្ឌខាងក្រោម ត្រូវបញ្ជូនទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលបានកំណត់៖

| ក្រុមមនុស្ស | រោគសញ្ញា | ផ្សេងៗ |
| --- | --- | --- |
| **ពេញវ័យ** | • កំហាប់អុកស៊ីសែនក្នុងឈាម < ៩៤%<br>• ហត់ ឬពិបាកដកដង្ហើម<br>• ឈឺទ្រូងខ្លាំង និងភ្លាមៗ<br>• ចង្វាក់ដង្ហើម > ២៥ដងក្នុង១នាទី<br>• សម្ពាធឈាមស៊ីស្តូលិក < ៩0mmHg<br>• វង្វេងស្មារតីទើបកើតមានថ្មីៗ (មិនមែនជាជំងឺចាស់វង្វេង)<br>• បាត់មាត់បាត់ក<br>• បញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ | មានសញ្ញា ១ ក្នុងចំណោមសញ្ញាទាំងអស់ ត្រូវបញ្ជូនអ្នកជំងឺកូវីដ-១៩ ទៅពេទ្យ |
| **កុមារ** | • កំហាប់អុកស៊ីសែនក្នុងឈាម < ៩៤%<br>• ហត់ដង្ហក់ ឬពិបាកដកដង្ហើម<br>• ដង្ហើមខ្លី ញាប់ ឬឮសូរចម្លែក ទ្រូងផតចូលខ្លាំង<br>• បបូរមាត់ និងមុខឡើងស្វាយ<br>• ឈឺទ្រូង<br>• វង្វេងវង្វាន់<br>• ដាស់មិនភ្ញាក់ ឬភ្ញាក់តែមិនមានប្រតិកម្មតប<br>• ល្ហិតល្ហៃ និងប្រកាច់<br>• មិនផឹក មិនបៅ ឬក្អួត និងសញ្ញាខ្វះជាតិទឹក | មានសញ្ញា ១ ក្នុងចំណោមសញ្ញាទាំងអស់ ត្រូវបញ្ជូនអ្នកជំងឺកូវីដ-១៩ ទៅពេទ្យ |

## ៧. គោលការណ៍អនុវត្តសម្រាប់អ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

អ្នកជំងឺកូវីដ-១៩ ដែលនៅដាច់ដោយឡែក និងសម្រាកព្យាបាលនៅផ្ទះ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមគោលការណ៍ខាងក្រោម៖

- អ្នកជំងឺត្រូវនៅក្នុងបន្ទប់ផ្ទះដាច់ដោយឡែកគ្រប់ពេលជារៀងរាល់ថ្ងៃ រហូតទទួលបានការអនុញ្ញាតឱ្យបញ្ចប់ការថែទាំព្យាបាលនៅផ្ទះ។
- **តាមដានរោគសញ្ញា៖** វាស់កំដៅជារៀងរាល់ថ្ងៃ នៅពេលព្រឹក និងពេលល្ងាច។ បើកំដៅលើសពី ៣៧.៥ អង្សារសេ ឬមានរោគសញ្ញាណាមួយដូចជា ហត់ ពិបាកដកដង្ហើម អស់កម្លាំងខ្លាំង វង្វេងវង្វាន់ វើវាយ ចុកទ្រូង ត្រូវឆាប់ទាក់ទងទៅគ្រូពេទ្យព្យាបាលដែលទទួលបន្ទុក។
- នៅដាច់ដោយឡែកពីសមាជិកគ្រួសារ៖
  - រស់នៅក្នុងបន្ទប់មួយដាច់ដោយឡែក ដែលមានខ្យល់ចេញចូលគ្រប់គ្រាន់ និងប្រើប្រាស់បន្ទប់ទឹក/បង្គន់ផ្សេងពីគ្រួសារ។ បរិភោគអាហារដាច់ដោយឡែកពីសមាជិកគ្រួសារ។
  - ពាក់ម៉ាសជាប់ជានិច្ច និងត្រូវរក្សាគម្លាតពីគ្នាយ៉ាងតិច ២ម៉ែត្រ ក្នុងពេលចាំបាច់ដែលត្រូវពិភាក្សាជាមួយសមាជិកក្នុងគ្រួសារ។
- ប្រើសម្ភារៈដាច់ដោយឡែកពីសមាជិកគ្រួសារ៖ ហាមប្រើសម្ភារៈរួមគ្នាជាមួយសមាជិកគ្រួសារដទៃទៀត។ លាងសម្អាតសម្ភារៈទាំងនោះជាមួយទឹកស្អាត និងសាប៊ូ ឱ្យបានស្អាតល្អបន្ទាប់ពីប្រើរួច។ បោកគក់សម្លៀកបំពាក់ឱ្យបានស្អាត និងហាលថ្ងៃឱ្យបានល្អ។
- អ្នកជំងឺត្រូវរក្សាអនាម័យខ្ជាប់ខ្ជួន ពាក់ម៉ាសគ្រប់ពេលវេលា ជាពិសេសអនាម័យផ្លូវដង្ហើម (ឧ. ខ្ទប់មាត់ច្រមុះនៅពេលក្អកដោយប្រើកែងដៃបត់ ឬក្រដាស់អនាម័យ ហើយចោលក្រដាស់អនាម័យនោះក្នុងធុងសម្រាមបានត្រឹមត្រូវ និងលាងសម្អាតដៃភ្លាមៗ)។
- បរិភោគម្ហូបអាហារដែលចម្អិនបានល្អ ម្ហូបអាហារមានជាតិត្រី សាច់ បន្លែ ផ្លែឈើ បន្ថយជាតិខ្លាញ់ ជាតិប្រៃ និងជាតិផ្អែម ដើម្បីជួយពង្រឹងប្រព័ន្ធការពារសារពាង្គកាយ។
- អនាម័យល្អក្នុងកន្លែងរស់នៅ និងរក្សាអារម្មណ៍នឹងនរ
  - ធ្វើកិច្ចការផ្សេងៗជាធម្មតា ហាត់ប្រាណក្នុងផ្ទះ សម្អាតបន្ទប់រស់នៅផ្ទាល់ខ្លួន បន្ទប់ទឹក ព្រមទាំងសម្ភារៈប្រើប្រាស់ផ្សេងៗជារៀងរាល់ថ្ងៃ។
  - សំណល់របស់អ្នកជំងឺ និងក្រុមគ្រួសារ ត្រូវទុកដាក់ដាច់ដោយឡែកពីគ្នា បិទឱ្យជិតល្អ ដើម្បីអាជ្ញាធរចាត់ចែងតាមនីតិវិធីនៃការគ្រប់គ្រងសំណល់ចម្លងរោគ។
- បញ្ចប់ការថែទាំព្យាបាលនៅតាមផ្ទះប្រសិនបើអ្នកជំងឺបានអនុវត្តត្រឹមត្រូវតាមវិធានការថែទាំព្យាបាល និងទទួលបានការជូនដំណឹងពីមន្ត្រីសុខាភិបាលនិងអាជ្ញាធរមូលដ្ឋាន។
- ទំនាក់ទំនងក្នុងករណីចាំបាច់ និងបន្ទាន់៖ សូមទាក់ទងទៅមន្ត្រីសុខាភិបាលដែលទទួលបន្ទុកនៅក្នុងមូលដ្ឋានរបស់អ្នក ឬទាក់ទងមកទូរសព្ទទាន់ហេតុការណ៍ (Hotline)។

## ៨. គោលការណ៍សម្រាប់គ្រូពេទ្យព្យាបាលដែលផ្តល់ការថែទាំព្យាបាលនៅតាមផ្ទះ

### ៨.១ វិធានការបង្ការនិងត្រួតពិនិត្យការចម្លងរោគសម្រាប់គ្រូពេទ្យព្យាបាល

1. កំណត់ពីឧបករណ៍ការពារខ្លួនចាំបាច់ដែលត្រូវប្រើក្នុងពេលព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ
2. រៀបចំអ្នកជំងឺកូវីដ-១៩ ស្នាក់នៅកន្លែងមានខ្យល់ចេញ-ចូល
3. ខ្យល់បរិយាកាសជាការប្រសើ បើមិនមានកន្លែងដែលមានខ្យល់ចេញ-ចូលទេ ត្រូវរៀបចំឱ្យមានកង្ហាសម្រាប់គាត់
4. រក្សាគម្លាតយ៉ាងតិច ២ម៉ែត្រ រវាងអ្នកជំងឺ និងក្រុមគ្រួសារ ក្នុងករណីចាំបាច់
5. ក្នុងពេលថែទាំ និងព្យាបាល ក្រុមគ្រូពេទ្យគួរស្ថិតក្នុងគម្លាតសុវត្ថិភាព បើចាំបាច់។ ត្រូវណែនាំឱ្យអ្នកជំងឺពាក់ម៉ាសឱ្យបានត្រឹមត្រូវ។

### ៨.២ ការតាមដានសញ្ញាគ្លីនិក និងការថែទាំព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

1. តាមដានកំដៅខ្លួន ភាពហត់ អស់កម្លាំង (fatigue) ក្អក (មានឬមិនមានស្លេស្ម) ឈឺសាច់ដុំ ឈឺក តឹងច្រមុះ និង ឈឺក្បាល។
2. តាមដានសុខភាពអ្នកជំងឺកូវីដ-១៩ ២ដងក្នុង១ថ្ងៃ តាមរយៈទូរសព្ទ
3. ត្រូវបញ្ជូនអ្នកជំងឺកូវីដ-១៩ ទៅមន្ទីរពេទ្យ ប្រសិនបើមានរោគសញ្ញាដូចតារាង ក្នុងចំណុចលេខ ៦.២
4. វាស់កំហាប់អុកស៊ីសែន ដោយប្រើ Pulse Oximeter។
5. ផ្តល់ការថែទាំ និងព្យាបាលរោគសញ្ញា៖ ថ្នាំបញ្ចុះកំដៅ ផ្តល់ដំបូន្មាននិងការណែនាំលើចំណីអាហារ ការបង្គ្រប់ជាតិទឹក និងជីវជាតិផ្សេងៗ
6. តាមដានសុខភាពខ្លួនឯងឱ្យបានទៀតទាត់។

### តារាងឱសថប្រើសម្រាប់ព្យាបាលជំងឺកូវីដ-១៩

| ភាពធ្ងន់ធ្ងរនៃលក្ខណៈគ្លីនិក | ការព្យាបាល | ធ្វើរោគវិនិច្ឆ័យ | តាមដាន | ទីកន្លែង |
|---|---|---|---|---|
| **ករណីគ្មានរោគសញ្ញា និងស្រាល** | • ដាក់ដាច់ដោយឡែក<br>• គាំទ្រផ្លូវចិត្ត<br>• បន្តព្យាបាលជំងឺប្រចាំកាយផ្សេងៗទៀត<br>• សូមទទួលទានអាហារ និងទឹកឱ្យបានគ្រប់គ្រាន់<br>• ព្យាបាលតាមរោគសញ្ញា<br>- ប៉ារ៉ាសេតាម៉ុល<br>- ឱសថប្រឆាំងមេរោគបើសង្ស័យថាមានការបង្ករោគដោយបាក់តេរី<br>- Antihistamine | • ត្រួតពិនិត្យសុខភាពដោយខ្លួនឯង<br>• ជូនដំណឹងគ្រឹះស្ថានសុខភាពដែលនៅក្បែរ | • កំដៅ >៣៧.៥<br>• ក្អក<br>• ឈឺបំពង់ក<br>• ហត់ ពិបាកដកដង្ហើម<br>• វង្វេងស្មារតី<br>• ចុកទ្រូង<br>• បាត់មាត់បាត់ក (ជាសញ្ញាវិវត្តទៅរកភាពធ្ងន់ធ្ងរ) | • ស្នាក់នៅផ្ទះខ្លួនឯង<br>• ធ្វើតេស្ត PCR នៅថ្ងៃទី ១៤ |

## តារាងសង្ខេបពីការគ្រប់គ្រងផ្នែកគ្លីនិក

| ចំណាត់ថ្នាក់គ្លីនិកនៃអន្តរាគមន៍ | គ្មានរោគសញ្ញា | ករណីស្រាល |
|---|---|---|
| ការបង្ការនិងការត្រួតពិនិត្យ ការចម្លងរោគ | X | X |
| ព្យាបាលតាមរោគសញ្ញា | | X |
| ការព្យាបាលគាំទ្រ | | |
| ការព្យាបាលដោយអុកស៊ីសែន | | |
| សារធាតុរាវ | | |
| ការព្យបាលដោយ **Corticosteroid** | | |
| Ramdesivir | | |
| ឱសថប្រឆាំងមេរោគបាក់តេរី (*) | | X |
| ការព្យាបាលដោយប្រើឱសថប្រឆាំងឈាមកក ( ** ) | | |
| ការគាំទ្រផ្លូវចិត្តនិងចិត្តសាស្ត្រ | X | X |

( * )ការសម្រេចចិត្តផ្អែកលើការវិនិច្ឆ័យគ្រូពេទ្យចំពោះអ្នកជំងឺដែលត្រូវសង្ស័យខ្លាំង ពីមានការឆ្លងមេរោគបន្ថែមពីលើកូវីដ-១៩។
( ** ) គោលការណ៍ណែនាំបណ្តោះអាសន្នរបស់អង្គការសុខភាពពិភពលោក បានណែនាំឱ្យប្រើឱសថប្រឆាំងឈាមកកដូចជា low molecular weight Heparin ដើម្បីការពារការស្ទះសរសៃឈាមវ៉ែន សម្រាប់អ្នកជំងឺសម្រាកពេទ្យ

## ៨.៣ សុខភាពផ្លូវចិត្ត និងការគាំទ្រផ្លូវចិត្ត

ការផ្តួចផ្តើមប្រាស្រ័យទាក់ទងយ៉ាងសកម្មជាមួយអ្នកជំងឺកូវីដ-១៩ និងក្រុមគ្រួសារដើម្បីផ្តល់ការគាំទ្រ និងព័ត៌មានពីការវិវឌ្ឍអាការៈរោគរបស់ជំងឺកូវីដ-១៩។ ស្វែងយល់ពីគុណតម្លៃ និងចំណង់ចំណូលចិត្តរបស់អ្នកជំងឺកូវីដ-១៩ ទាក់ទងនឹងអន្តរាគមន៍ដែលជួយទ្រទ្រង់ និងថែទាំជីវិត។ អ្នកជំងឺកូវីដ-១៩ និងក្រុមគ្រួសារអ្នកជំងឺកូវីដ-១៩ ជារឿយៗទទួលរងពីការថប់បារម្ភ និងការភ័យខ្លាច ដែលពួកគាត់គួរតែត្រូវបានគាំទ្រដោយការប្រឹក្សាខាងផ្លូវចិត្ត។

រោគសញ្ញានៃការថប់បារម្ភ និងបាក់ទឹកចិត្ត អាចជាប្រតិកម្មទូទៅរបស់មនុស្សក្នុងបរិបទនៃការធ្វើរោគវិនិច្ឆ័យជំងឺកូវីដ-១៩ ជាពិសេសចំពោះអ្នកដែលអាចត្រូវសម្រាកពេទ្យ ដោយសារការបារម្ភចំពោះសុខភាពផ្ទាល់ខ្លួន ឬសុខភាពអ្នកដទៃ ឬការតម្រូវឱ្យដាក់នៅដាច់ដោយឡែក (ដែលនាំឱ្យមានការផ្តាច់ចេញពីសហគមន៍) ការប្រឈមនឹងហានិភ័យនៃការស្លាប់ដែលអាចកើតឡើង បារម្ភចំពោះហានិភ័យនៃការឆ្លងទៅអ្នកដទៃ និងបារម្ភពីការទុកចោលគ្រួសារដែលត្រូវការថែទាំឱ្យនៅតែឯង។

ផ្តល់ការគាំទ្រផ្លូវចិត្ត និងសុខភាពផ្លូវចិត្តជាមូលដ្ឋាន ដល់គ្រប់អ្នកដែលសង្ស័យឬបញ្ជាក់កូវីដ-១៩ ដោយសាកសួរពួកគាត់ពីសេចក្តីត្រូវការ និងការបារម្ភ ហើយដោះស្រាយជូនគាត់។

កំណត់ឱ្យបានឆាប់ និងវាយតម្លៃនូវរោគសញ្ញាថប់បារម្ភ បាក់ទឹកចិត្តក្នុងបរិបទជំងឺកូវីដ-១៩ ចាប់ផ្តើមយុទ្ធសាស្ត្រគាំទ្រផ្លូវចិត្ត អន្តរាគមន៍ជួរទីមួយដើម្បីការព្យាបាលរោគសញ្ញាថ្មីនៃការថប់បារម្ភ និងបាក់ទឹកចិត្ត។

ប្រើយុទ្ធសាស្ត្រគាំទ្រផ្លូវចិត្តជាអន្តរាគមន៍ជួរទីមួយ ដើម្បីការព្យាបាលបញ្ហាដំណេក ក្នុងករណីស្ត្រេសស្រួចស្រាវ។

### ៨.៤ ការអនុញ្ញាតឱ្យបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

1. ការយកសំណាកពីច្រមុះ និងបំពង់ក ត្រូវធ្វើនៅថ្ងៃទី១៤ បន្ទាប់ពីការបញ្ជាក់លទ្ធផលវិជ្ជមាន ដោយប្រកាន់យកដូចខាងក្រោម៖
   - ក្នុងករណីលទ្ធផលអវិជ្ជមាន គឺគាត់អាចបញ្ចប់ការព្យាបាលនៅផ្ទះបាន។
   - បើលទ្ធផលវិជ្ជមាន ត្រូវនៅធ្វើតេស្តម្តងទៀតនៅ ៤៨ម៉ោងក្រោយ។ ក្នុងករណីលទ្ធផលអវិជ្ជមាន នោះអ្នកជំងឺត្រូវអនុញ្ញាតឱ្យបញ្ចប់ការព្យាបាលនៅផ្ទះបាន។
2. ទោះជាបញ្ចប់ការព្យាបាល ក៏ត្រូវឱ្យបន្តធ្វើចត្តាឡីស័កនៅផ្ទះរបស់គាត់ក្នុងរយៈពេល ១៤ ថ្ងៃទៀត និងធ្វើតេស្តឡើងវិញ នៅថ្ងៃទី១៣ នៃថ្ងៃធ្វើចត្តាឡីស័ក ដោយប្រកាន់យកដូចខាងក្រោម៖
   - ក្នុងករណីលទ្ធផលអវិជ្ជមាន គឺគាត់អាចបញ្ចប់ការធ្វើចត្តាឡីស័កនៅផ្ទះបាន។
   - ក្នុងករណីតេស្តបង្ហាញវិជ្ជមាន អ្នកជំងឺត្រូវបន្តព្យាបាលឡើងវិញ ដូចដំណើរការនៃការចាប់ផ្តើមព្យាបាលដំបូង ដោយត្រូវតាមដានធ្វើតេស្តម្តងទៀតនៅ ១៤ថ្ងៃក្រោយ។

### ៨.៥ ការគ្រប់គ្រងអ្នកពាក់ព័ន្ធជាមួយអ្នកជំងឺកូវីដ-១៩

1. ហាមជួបសួរសុខទុក្ខដោយផ្ទាល់
2. ហាមប៉ះពាល់សត្វ
3. កាត់បន្ថយការជួបសមាជិកក្នុងគ្រួសារ
4. ត្រូវពាក់ម៉ាស និងរក្សាគម្លាត ២ម៉ែត្រ ក្នុងករណីចាំបាច់ជួបប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ឬអាជ្ញាធរ។

## ៩. គោលការណ៍ស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគសម្រាប់អ្នកថែទាំដែលផ្តល់ការថែទាំព្យាបាលនៅតាមផ្ទះ

- កម្រិតដែនកំណត់នៃការបម្លាស់ទីរបស់អ្នកជំងឺកូវីដ-១៩ នៅក្នុងផ្ទះ។
- សមាជិកគ្រួសារត្រូវចៀសវាងចូលក្នុងបន្ទប់អ្នកជំងឺកូវីដ-១៩។ ប្រសិនបើចាំបាច់ត្រូវចូល អ្នកជំងឺកូវីដ-១៩ និងសមាជិកគ្រួសារត្រូវពាក់ម៉ាស រក្សាគម្លាតសុវត្ថិភាព (២ម៉ែត្រឡើង)។
- កំណត់ចំនួនអ្នកថែទាំឱ្យបានតិចបំផុត ហើយល្អបំផុត គួរចាត់តាំងបុគ្គលម្នាក់ដែលមានសុខភាពល្អ ដែលពុំមានស្ថានភាពជំងឺរ៉ាំរ៉ៃ ឬប្រព័ន្ធស៊ាំខ្សោយ។
- មិនត្រូវអនុញ្ញាតឱ្យមានអ្នកមកសួរសុខទុក្ខឡើយ រហូតទាល់តែអ្នកជំងឺកូវីដ-១៩ បានជាសះស្បើយ លែងមានរោគសញ្ញាទាំងស្រុង និងបញ្ឈប់ពីការដាក់ដោយឡែក។
- លាងសម្អាតដៃឱ្យបានត្រឹមត្រូវ មុនពេល និងបន្ទាប់ពីបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ គ្រប់ការធ្វើទម្រង់ការ ឬក្រោយពីប៉ះពាល់ទឹករំអិលផ្សេងៗ ឬបរិស្ថានផ្ទាល់ជុំវិញអ្នកជំងឺកូវីដ-១៩។ សូមមើល " ពេលវេលាទាំងប្រាំនៃអនាម័យដៃ" ។

- ត្រូវធ្វើអនាម័យដៃនៅមុន និងក្រោយពេលរៀបចំចម្អិនម្ហូបអាហារ មុនពេលបរិភោគ ក្រោយពេលបន្ទោរបង់ និងនៅពេលដែលដៃកខ្វក់។ ប្រសិនបើដៃមើលទៅមិនកខ្វក់ទេនោះ អាចប្រើប្រាស់ទឹកអាល់កុលលាងដៃដើម្បីសម្លាប់មេរោគក៏បាន។ សម្រាប់ដៃដែលមើលទៅកខ្វក់ ត្រូវលាងសម្អាតដៃជាមួយទឹក និងសាប៊ូ។
- ត្រូវផ្តល់ម៉ាសដល់អ្នកជំងឺកូវីដ-១៩ ហើយឱ្យអ្នកជំងឺពាក់ឱ្យបានជាប់លាប់តាមដែលអាចធ្វើទៅបាន និងត្រូវផ្លាស់ប្តូរជារៀងរាល់ថ្ងៃ ឬនៅពេលសើមឬកខ្វក់។ អ្នកជំងឺកូវីដ-១៩ ដែលមិនអាចទ្រាំនឹងការពាក់ម៉ាសបាន គួរតែប្រើប្រាស់វិធីបង្ការអនាម័យផ្លូវដង្ហើមឱ្យបានខ្ជាប់ខ្ជួន ដែលត្រូវខ្ទប់មាត់ និងច្រមុះឱ្យជិតដោយក្រដាសប្រើហើយបោះចោលនៅពេលក្អក ឬកណ្តាស់ម្តងៗ។
- របស់របរដែលប្រើប្រាស់ដើម្បីខ្ទប់មាត់ និងច្រមុះត្រូវតែវេចខ្ទប់ឱ្យបានត្រឹមត្រូវដើម្បីកំទេចចោល ឬសម្អាតឱ្យស្អាតត្រឹមត្រូវបន្ទាប់ពីប្រើប្រាស់ហើយ (ឧ. ត្រូវបោកសម្អាតកន្សែងដៃជាមួយនឹងសាប៊ូ ឬម្សៅសាប៊ូធម្មតាជាមួយនឹងទឹក)។
- អ្នកផ្តល់ការថែទាំត្រូវតែពាក់ម៉ាសដែលរឹតណែនជាប់ល្អដើម្បីគ្របមាត់និងច្រមុះឱ្យជិតល្អនៅពេលស្ថិតនៅក្នុងបន្ទប់តែមួយជាមួយនឹងអ្នកជំងឺកូវីដ-១៩។ ហាមយកដៃទៅប៉ះ ឬកាន់ម៉ាសនៅពេលកំពុងពាក់ជាប់លើមុខ។ ប្រសិនបើម៉ាសសើម ឬកខ្វក់ដោយសារសំណើមឬទឹករំអិល ត្រូវប្តូរម៉ាសនោះចេញ ហើយពាក់ម៉ាសថ្មីដែលស្អាត និងស្ងួតជាបន្ទាន់។ ត្រូវដោះម៉ាសតាមបច្ចេកទេសដោះម៉ាសសមស្រប ដែលមិនត្រូវយកដៃទៅប៉ះនឹងផ្នែកខាងមុខរបស់ម៉ាសឡើយ ប៉ុន្តែត្រូវដោះម៉ាសនោះចេញឱ្យបានត្រឹមត្រូវ ហើយត្រូវបោះម៉ាសនោះចោលភ្លាមបន្ទាប់ពីប្រើហើយ និងត្រូវលាងសម្អាតដៃឱ្យបានត្រឹមត្រូវ។
- មិនត្រូវប៉ះពាល់ដោយផ្ទាល់ជាមួយនឹងសារធាតុរាវចេញពីខ្លួនប្រាណអ្នកជំងឺកូវីដ-១៩ ជាពិសេសតំណក់តូចៗចេញពីមាត់ ឬការដកដង្ហើម និងលាមកឡើយ។ ត្រូវប្រើប្រាស់ស្រោមដៃប្រើម្តងហើយបោះចោល និងម៉ាសនៅពេលផ្តល់ការថែទាំមាត់ ឬផ្លូវដង្ហើម និងនៅពេលចាត់ចែងជាមួយនឹងលាមក ទឹកនោម និងសំណល់ផ្សេងទៀតរបស់អ្នកជំងឺកូវីដ-១៩។ ត្រូវលាងសម្អាតដៃនៅមុនពាក់ និងបន្ទាប់ពីដោះស្រោមដៃ និងម៉ាសចេញ។
- មិនត្រូវប្រើប្រាស់ម៉ាស ឬស្រោមដៃឡើងវិញឡើយ។ ត្រូវបោះស្រោមដៃដែលបានប្រើរួចចោលក្នុងធុងសម្រាម និងធ្វើអនាម័យដៃ មុននិងក្រោយពេលពាក់។
- នៅពេលសម្អាតផ្ទៃ ឬរៀបចំសម្អាតសម្ភារៈអ្នកជំងឺកូវីដ-១៩ ដែលប្រឡាក់ អ្នកកំដរថែទាំត្រូវប្រើប្រាស់ស្រោមដៃ (ប្រើម្តងបោះចោល) និងអាវអៀមការពារ។
- សម្អាត និងសម្លាប់មេរោគនៅលើផ្ទៃនានាជារៀងរាល់ថ្ងៃដែលជាទីកន្លែងត្រូវបានប៉ះជាញឹកញាប់នៅក្នុងបន្ទប់ដែលប្រើប្រាស់សម្រាប់ថែទាំអ្នកជំងឺកូវីដ-១៩ ដូចជា តុដាក់ជាប់នឹងគ្រែ គ្រោងគ្រែគេង និងគ្រឿងសង្ហារឹមនានានៅក្នុងបន្ទប់គេង។
- លាងសម្អាត និងសម្លាប់មេរោគផ្ទៃបន្ទប់ទឹក និងបង្គន់យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។ ដំបូងត្រូវលាងសម្អាតជាមួយនឹងសាប៊ូ ឬម្សៅសាប៊ូធម្មតាជាមុនសិន ហើយបន្ទាប់ពីបានជូតទឹកជម្រះសម្អាតហើយ គួរប្រើសារធាតុកម្ចាត់មេរោគធម្មតាដែលមានសារធាតុ សូដ្យូមអ៊ីប៉ូក្លរីត 0.១% (ស្មើនឹង ១000 ppm)។

- ប្រដាប់ប្រដារប្រើប្រាស់របស់អ្នកជំងឺ (ពូក ខ្នើយ កម្រាលពូក ចានស្លាបព្រា ។ល។) ត្រូវមានដាច់ដោយឡែកពីសមាជិកគ្រួសារដទៃទៀត ហើយអាចលាងសម្អាតសម្រាប់ប្រើប្រាស់ឡើងវិញ។
- ត្រូវដាក់កម្រាលពូក និងស្រោមខ្នើយដែលប្រឡាក់នៅក្នុងថង់សម្រាប់ទុកបោកគក់។ មិនត្រូវក្រឡុកសម្លៀកបំពាកប្រឡាក់សម្រាប់ទុកបោកគក់ឡើយ ហើយមិនត្រូវឱ្យរបស់របរប្រឡាក់ទាំងនេះប៉ះត្រូវនឹងស្បែក និងសម្លៀកបំពាក់ឡើយ។
- សម្អាតសម្លៀកបំពាក់របស់អ្នកជំងឺ កម្រាលពូក និងស្រោមខ្នើយ និងបន្ទប់ទឹក និងកន្សែងដៃជាមួយនឹងសាប៊ូ និងទឹក ឬប្រើម៉ាស៊ីនបោកគក់ក្នុងកម្រិតកំដៅចន្លោះចាប់ពី 60–90°C ជាមួយម្សៅសាប៊ូប្រើប្រាស់តាមផ្ទះធម្មតា។ ដាក់ហាលសម្ងួតឱ្យស្ងួតល្អ។
- រាល់សំណល់ទាំងឡាយដែលមានពីការថែទាំអ្នកជំងឺនៅផ្ទះ ត្រូវទុកដាក់ឱ្យបានត្រឹមត្រូវ។

## ១០.គោលការណ៍ និងបទដ្ឋានប្រតិបត្តិសម្រាប់កម្លាំងគាំទ្រ ដូចជាអាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ

1. គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពស្ថិតិអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ និងរក្សាទុកឯកសារសម្រាប់ប្រើ ប្រាស់នៅពេលត្រូវការ (ឧទាហរណ៍ ប្រាក់ឧបត្ថម្ភ)
2. ការពារអ្នកក្រៅចូលមកលេងនៅក្នុងផ្ទះអ្នកជំងឺកូវីដ-១៩
3. ការពារសមាជិកស្នាក់នៅផ្ទះជាមួយចេញទៅក្រៅ
4. ការពារអ្នកជំងឺកូវីដ-១៩ ចេញដើរទៅក្រៅក្នុងអំឡុងពេលព្យាបាលជំងឺកូវីដ-១៩
5. រក្សាសន្តិសុខ និងសុវត្ថិភាពនៅទីកន្លែងព្យាបាលអ្នកជំងឺកូវីដ-១៩ ស្នាក់នៅ
6. រក្សាការប្រាស្រ័យទាក់ទងជាមួយមណ្ឌលសុខភាព និងការិយាល័យស្រុកប្រតិបត្តិ។